# ឧបករណ៍តន្ត្រីខ្មែរ "ខ្សែមួយ"

ព្រះរាជាណាចក្រកម្ពុជា ប្រកបដោយសម្បត្តិវប្បធម៌សម្បូណ៌បែប រួមមានទាំងឧបករណ៍តន្ត្រីជាច្រើនប្រភេទ ដែលជាផ្នែកមួយនៃអត្តសញ្ញាណវប្បធម៌ខ្មែរ។ ប្រជាជនខ្មែរជាទូទៅនិយមហៅឧបករណ៍តន្ត្រីខ្សែមួយថា "**ខ្សែដៀវ សាយដៀវ ឬសាដៀវ**" ជាភាសាថៃឬខ្មែរលាយថៃ។ ជាតុពិត ឧបករណ៍តន្ត្រីនេះ ជាមរតកតន្ត្រីកេរតំណែលដូនតាខ្មែរសុទ្ធសាធ។ យើងគួរកត់សម្គាល់ថា ឧបករណ៍ខ្សែមួយ ត្រូវបានបុព្វបុរសខ្មែរឆ្លាក់ជាប់នៅលើជញ្ជាំងប្រាសាទបុរាណ មានប្រាសាទបាយ័នជាតឹកតាង (ចុងសតវត្សទី១២ឬដើមសតវត្សទី១៣) (រូបលេខ១)។

"**សាយ**" មានន័យថា "**ខ្សែ**" គឺសំណុំសរសៃសូត្រតូច ដែលចងតពីក្បាលស្ពាបឯកភ្ជាប់នឹងចុងដង ពោលគឺសាយឯកឬឯកដាច់សាយ។ រីឯពាក្យ "**ដៀវ**" មានន័យថា "**មួយឬតែមួយ**"។ បើតាមវចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត ឱ្យនិយមន័យលើឧបករណ៍តន្ត្រីនេះថា ជាឈ្មោះគ្រឿងតន្ត្រីមួយប្រភេទ មានខ្សែលួសស្ពាន់តែមួយ មានសំបកឃ្លោកមូលមួយកំណាត់ទ្រភ្ជាប់ពីក្រោមដង មានប៉ោលសម្រាប់រឹតឬបន្ធូរខ្សែ ប្រើជាគ្រឿងដេញមានសូរសព្ទមូលរងំ។ សម្ដេចព្រះសង្ឃរាជក៏បានណែនាំថា យើងគួរហៅឧបករណ៍តន្ត្រីនេះថា "**ខ្សែមួយឬឯកតន្ត្រី, ដេញឯកតន្ត្រី សូរឯកតន្ត្រី**"។[១]

## ឧបករណ៍

ឧបករណ៍ខ្សែ១ មានបណ្ដោយដងធ្វើពីឈើក្រញូង បេងឬនាងនួន ប្រវែង ០.៨០ម ដែលនៅខាងចុងមានរាងកោងបន្តិច និងមានឆ្លាក់ក្បាច់រូបសត្វដូចជានាគឬហង្ស ធ្វើពីឈើ ស្នាច់ ឆ្អឹង ឬភ្លុកជាគ្រឿងលម្អ។ ឯប្រអប់សូរធ្វើដោយសំបកឃ្លោកទុំស្ងួត មានវិជ្ឈមាត្រឬបន្ទាត់ផ្ចិត ប្រវែង ០.២០ម និងមានខ្សែស្ពាន់តែមួយសរសៃសន្ធឹងពីចុងដងទៅព្រលួត

---

[១] ជួន ១៩៦៧: ១៣២៦, ១៣៣៦

អត្ថបទដោយ៖ លោកបណ្ឌិត សំ សំអាង

នៅប្រហែលជាពីរភាគបីពីចុងដង ជិតទៅខាងព្រលួត គេចងសំបកឃ្លោកភ្ជាប់ទៅនឹងដង ដោយមានខ្សែដាក់បញ្ចូលទៅក្នុង តាមរន្ធផ្ទៃឃ្លោកភ្ជាប់ដោយកន្ទាស់ពីខាងក្នុង ហើយ យកខ្សែលួសមួយសរសៃចងរឹតខ្សែស្ពាន់ឲ្យជាប់ទៅនឹងដង ធ្វើជាខ្សែក ត្រង់កន្លែងដែល ភ្ជាប់សំបកឃ្លោក ដោយមិនមានពាសស្បែកអ្វីទេ(រូបលេខ២)។ នៅក្នុងវង់តន្ត្រីអារក្សឬ អាពាហ៍ពិពាហ៍ឧបករណ៍ខ្សែមួយ រឹតទៅតាមឧបករណ៍ប៉ីប្រុសដែលជាឧបករណ៍មាន សូរនឹង មិនផ្លាស់ប្តូរ (Fixed pitch)។[២]

## របៀបសម្តែង

នៅពេលសម្តែង អ្នកដេញយកសំបកឃ្លោកមកផ្ទប់នឹងដើមទ្រូង ហើយបង្អើបឬ ផ្អឹបសំបកឃ្លោកទៅនឹងទ្រូង ដើម្បីផ្លាស់ប្តូរសូរទៅតាមបទ។ គេកេះខ្សែស្ពាន់តែមួយនោះ ដោយប្រើក្រចកដែកដែលអ្នកដេញពាក់ស៊កទៅលើម្រាមដៃមួយដើម្បីឱ្យឮសូរខ្លាំង **"តូម តូម"** ផ្តក់មួយៗនៅមុនឬក្រោយចង្វាក់បន្តិច (Syncopation) (រូបលេខ៣)។

## របៀបប្រើ៖

គេប្រើឧបករណ៍ខ្សែមួយ ដែលមានសូរតម្អូញលន្វង់លន្វោចនៅពេលយប់ស្ងាត់ ឬ នារដូវស្រូវទុំ ដែលខ្មែរយើងអ្នកស្រែចម្ការនិយមដេញលេងកម្សាន្តនៅពេលចាំស្រូវនៅ ខ្ទមស្រែ។ ក្រៅពីការសម្តែងទោល គេប្រើឧបករណ៍ខ្សែមួយ នៅក្នុងវង់តន្ត្រីអារក្សនិង អាពាហ៍ពិពាហ៍។

តាមការស្រាវជ្រាវផ្នែកជាតិពន្ធុតន្ត្រីវិទ្យា (Ethnomusicology) គេអាចសន្មតថា ឧបករណ៍តន្ត្រីដែលមានខ្សែតែមួយ ដូចជាឧបករណ៍ **"ធ្នូតន្ត្រី"** (Musical bow) ជាឧបករណ៍ តន្ត្រីចាស់ជាងគេ ដែលឧបករណ៍តន្ត្រីឯទៀតៗកើតឡើងនិងបំបែកខ្លួន។[៣] ឈរនៅលើ ទស្សនៈនេះ ឧបករណ៍តន្ត្រីខ្មែរមានម៉ុមនិងខ្សែមួយ ដែលបុព្វបុរសយើងបានធ្លាក់នៅលើ

---

[២] *Musique Khmère* 1969: 52

[៣] Chonpairot 1981: 100

ជញ្ជាំងប្រាសាទបាយ័ន យើងក៏អាចសន្មតថាជាឧបករណ៍តន្ត្រីពីរ ដែលមានអាយុកាលចាស់ជាងឧបករណ៍តន្ត្រីគ្រឿងខ្សែនៅប្រទេសកម្ពុជាដែរ។

## ឯកសារពិគ្រោះ


**កែវ, ណារុំ.**

២០១១. *តន្ត្រីនៅប្រទេសខ្មែរ*. ភ្នំពេញ: គ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្ត។

**ជួន ណាត.**

១៩៦៧. *វចនានុក្រមខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

**ពេជ្រ សល់.**

១៩៧០. *អំពីលំនាំសង្វេបនៃភ្លេងខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

**Chonpairot, Jarernchai.**

1981. "The Diffusion of the Vina in Southeast Asia," *Proceedings of the Saint Thyagaraja Music Festival*. Cleveland: Greater Cleveland Ethnographic Museum, 98-108.

**Musique Khmère.**

1969. Phnom Penh: Imprimerie Sangkum Réastr Niyum.

**Sam, Sam-Ang.**

2002. *Musical Instruments of Cambodia*. Osaka: National Museum of Ethnology.


អត្ថបទដោយ៖ លោកបណ្ឌិត សំ សំអាង



រូបលេខ១៖ ការលេងឧបករណ៍ខ្សែមួយឬខ្សែដៀវលើចម្លាក់ប្រាសាទបាយ័ន្ត



រូបលេខ២៖ ឧបករណ៍ឬខ្សែមួយឬខ្សែដៀវ



រូបលេខ៣៖ សកម្មភាពសំដែង
ឧបករណ៍ខ្សែមួយឬខ្សែដៀវ

អត្ថបទដោយ៖ លោកបណ្ឌិត សំ សំអាង